ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សូមគោរពជូន
# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
# និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

**តាមរយៈ:** លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ:** របាយការណ៍សង្ខេបស្តីពី ពិធីបញ្ចុះបឋមសិលាកសាងមណ្ឌលទទួលពលករវិលត្រឡប់ពីប្រទេសថៃតាមច្រកទ្វារព្រំដែន នៃខេត្តបាត់ដំបង ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៩ និង ៣០ នាទីព្រឹក នៅភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មានរៀបចំពិធីបញ្ចុះបឋមសិលាកសាងមណ្ឌលទទួលពលករវិលត្រឡប់ពីប្រទេសថៃតាមច្រកទ្វារព្រំដែន នៃខេត្តបាត់ដំបងក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

## I.សមាសភាពចូលរួម

១.លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

២.លោក ម៉ាក ភ្លកល័រ នាយកប្រចាំប្រទេសអង្គការការីតាស់ស្វីស

៣.លោកជំទាវ ស៊ុំ ចិន្តា អភិបាលរងខេត្តបាត់ដំបង

៤.លោកជំទាវ យូ សុភា អភិបាលរងខេត្តសៀមរាប

៥.លោកជំទាវ ប៉ុក ណាឌី អភិបាលរងខេត្តបន្ទាយមានជ័យ

៦.ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ

៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង គ.ជ.ប.ជ

៨.លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង

៩.លោកស្រី ព្រុំ សុខន ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១០.លោកឧត្តមសេនីយ៍ទោ សេក ស៊ីវ៉េត ប្រធានក្រុមការងារការពារជនរងគ្រោះ(គ.ជ.ប.ជ)

១១.លោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ(គ.ជ.ប.ជ)

១២.លោក សុខ គឹមខុន អភិបាល នៃគណៈអភិបាលស្រុកកំរៀង

១៣.លោកប្រធានក្រុមប្រឹក្សាស្រុកកំរៀង

១៤.លោកមេឃុំក្នុងស្រុកកំរៀង

១៥.មន្ត្រីមានសមត្ថកិច្ចក្នុងស្រុកកំរៀង( នគរបាល កងរាជអាវុធហត្ថ និងយោធា )

១៦.មន្ត្រីសមត្ថកិច្ចច្រកទ្វារព្រំដែនខេត្តបាត់ដំបង

១៧.ព្រះសង្ឃ តាជី យាយជី

១៨.ក្រុមវិស្វករសាងសង់មណ្ឌល

១៦.ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមន្ត្រីពាក់ព័ន្ធសរុបប្រមាណ ៥០ រូប។

**II.កម្មពិធីបញ្ចុះបឋមសិលា**

វេលាម៉ោង ៩ និង ៣០នាទីព្រឹក កម្មពិធីបញ្ចុះបឋមសិលាបានចាប់ផ្តើមដោយព្រះសង្ឃសូត្រមន្តបែបសាសនា និងពិធីសុំម្ចាស់ទឹក ម្ចាស់ដី ប្រោសព្រំសុំសេចក្តីសុខក្នុងដំណើរការ នៃការសាងសង់មណ្ឌលទទួលពលករ។

**III.មតិស្វាគមន៍ និងសណោះសំណាល**

បន្ទាប់ពីពិធីបញ្ចុះបឋមសិលាបានបញ្ចប់រួចរាល់ **លោក សុខ គឹមខុន** អភិបាល នៃគណៈអភិបាលស្រុកកំរៀង បានមានមតិស្វាគមន៍ចំពោះ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលមានវត្តមានក្នុងពេលនេះ ។ លោកអភិបាលស្រុកបានធ្វើសេចក្តីរាយការណ៍សង្ខេបអំពីស្ថានភាពភូមិសាស្ត្រនៅក្នុងស្រុកកំរៀង និងការអនុវត្តការងារទទួលពលករ ការគ្រប់គ្រងពលករចេញ-ចូល តាមច្រកទ្វារព្រំដែនក្នុងពេលវិបត្តិកូវីដ-១៩ ជូន អង្គពិធី ។

**លោក ម៉ាក ក្លកល័រ** នាយកប្រចាំប្រទេសអង្គការការីតាស់ស្វីស មានមតិចូលរួមក្នុងពិធីបញ្ចុះបឋមសិលាកសាងមណ្ឌលទទួលពលករដែលវិលត្រឡប់ពីប្រទេសថៃ ថាៈ ការកសាងមណ្ឌលទទួលពលករនេះ គឺទទួលបានពីការជួយឧបត្ថម្ភផ្ទាល់ពីអង្គការការីតាស់ស្វីស តែមួយគត់ ដោយមានការចូលរួមសហការពីរាជរដ្ឋាភិបាលកម្ពុជា និងមានការសម្របសម្រួលពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ លោក ម៉ាក ក្លកល័រ មានមតិបញ្ជាក់ថា សព្វថ្ងៃនេះមានអង្គការការីតាស់ ជាច្រើនប្រទេស ដែលបានមកឈរជើងនៅក្នុងប្រទេសកម្ពុជា ។ **លោកម៉ាក ក្លកល័រ** មានមតិថ្លែងអំណរគុណចំពោះម្ចាស់ទីតាំងដែលបានផ្តល់ដីមួយកន្លែងនេះ សម្រាប់សាងសង់មណ្ឌលទទួលពលករ សូមអរគុណចំពោះ គ.ជ.ប.ជ និងការចូលរួមពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ក្នុងការយកចិត្តទុកដាក់លើការងារនេះ ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍សំណេះសំណាល និងផ្តាំផ្ញើក្នុងពិធីបញ្ចុះបឋមសិលាកសាងមណ្ឌលទទួលពលករថា សូមអរគុណចំពោះការជួយឧបត្ថម្ភក្នុងការកសាងមណ្ឌលទទួលពលកររបស់អង្គការការីតាស់ស្វីស អរគុណចំពោះម្ចាស់ទីតាំងដែលបានផ្តល់ដីទំហំ ១០០ម៉ែត្រ គុណនឹង ៥០ម៉ែត្រ ដែលនឹងត្រូវសាងសង់អគារទទួលពលករ មានទំហំ ១០ម៉ែត្រ

គុណនឹង ៣០ម៉ែត្រ សម្រាប់ជាផលប្រយោជន៍ក្នុងការជួយដោះស្រាយផលពិបាកជូនពលករដែលបានវិលត្រឡប់មកពីប្រទេសថៃតាមច្រកទ្វារព្រំដែនក្នុងខេត្តបាត់ដំបងជាបណ្តោះអាសន្ន ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា ក្រោយពីសាងសង់មណ្ឌលនេះរួចរាល់ និងបានដំណើរការ គឺស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ខ.ប.ជ) នៃខេត្តបាត់ដំបង ។

ចុងបញ្ចប់ **លោកជំទាវ រដ្ឋលេខាធិការ** មានប្រសាសន៍ផ្តាំផ្ញើថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា យើងទាំងអស់គ្នាត្រូវចូលរួមសហការក្នុងការថែរក្សាការពារសមិទ្ធិផលនេះ និងអនុវត្តការងារទៅតាមតួនាទីភារកិច្ចដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ជូនប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃ ៧ ៦ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់
ថ្ងៃ ព្រហ ៦ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណា សំខាន់

បានឃើញ
29/07/2020